**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៩៩៦ សហវ.អថ

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែសីហា ឆ្នាំ ២០១៦

**គោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា**

**<u>កម្មវត្ថុ</u>៖** ករណីសំណើសុំអនុញ្ញាតជាគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីអប់រំ ដែលពាក់ព័ន្ធនឹងអង្គភាពមួយចំនួនអាចចុះបំពេញបេសកកម្មក្នុងប្រទេសលើសពី ១០ ថ្ងៃ រហូតដល់ក្រោម ២០ ថ្ងៃ ក្នុងមួយខែ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០១៦ និង បណ្តាឆ្នាំខាងមុខ។

**<u>យោង</u>៖** លិខិតលេខ ២៨៩៦អយក.ហវ ចុះថ្ងៃទី ០៨-០៦-២០១៦ របស់ក្រសួងអប់រំ យុវជន និងកីឡា ។

តបតាមន័យដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាប **ឯកឧត្តមរដ្ឋមន្ត្រី**មេត្តាជ្រាបថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មិនអនុញ្ញាតជាគោលការណ៍ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការរបស់ក្រសួងអប់រំយុវជន និងកីឡា សម្រាប់ការចុះបំពេញបេសកកម្មក្នុងប្រទេសលើសពី ១០ ថ្ងៃ រហូតដល់ក្រោម ២០ ថ្ងៃ ក្នុងមួយខែ សម្រាប់ការអនុវត្តថវិកាឆ្នាំ២០១៦ និងឆ្នាំបន្តបន្ទាប់ទេ ដោយសារមិនមានមូលហេតុច្បាស់លាស់ដើម្បីគាំទ្រសំណើខាងនេះ ។ ក្នុងន័យនេះ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវស្នើសុំទិដ្ឋាការពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមករណីជាក់ស្តែងនីមួយៗដោយអនុលោមតាមសារាចរលេខ ០១២ ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីគោលការណ៍ណែនាំបន្ថែមលើរយៈពេល សោហ៊ុយធ្វើដំណើរ តម្លៃសំបុត្រយន្តហោះ ចំពោះការបំពេញបេសកកម្មនៅក្នុងនិងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ ។ ទន្ទឹមគ្នានេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ៖

១- បានអនុញ្ញាតជាគោលការណ៍ ជូនមន្ត្រីចំនួន០៧រូប នៃនាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន អាចបំពេញបេសកកម្មលើសពី១០ ថ្ងៃ ក្នុងមួយខែ សម្រាប់ឆ្នាំ២០១៦ នេះ ដើម្បីអនុវត្តការងារឱ្យបានទាន់ពេលវេលានិងមានប្រសិទ្ធភាព តាមរយៈលិខិតលេខ ២៩១២ សហវ.អថ ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៦ ហើយគោលការណ៍អនុញ្ញាតនោះ នៅមានសុពលភាពអនុវត្តនៅឡើយ ។

២- បានឯកភាពគ្នា និងកំពុងរៀបចំសេចក្តីព្រាងប្រកាសអន្តរក្រសួង ស្តីពីនីតិវិធីអនុវត្តចំណាយថវិកាសម្រាប់ឧបត្ថម្ភដល់ក្រុមមន្ត្រីវាយតម្លៃសម្រាប់ចុះវាយតម្លៃផ្តល់ការទទួលស្គាល់គុណភាពអប់រំលើគ្រឹះស្ថានឧត្តមសិក្សា នៃគណៈកម្មការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ដើម្បីដោះស្រាយ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St. 92, Sangkat Wat Phnom , Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ ៖ ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ ៖ ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ការលំបាកក្នុងការអនុវត្តកន្លងមក រួមទាំងការចុះបំពេញបេសកកម្មនេះផងដែរ ។ សម្រាប់ឆ្នាំ២០១៦ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញលិខិតលេខ៤៨៩២ សហវ.អថ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០១៦ ដើម្បីអនុវត្ត។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាបនិងចាត់ចែងតាមការគួរ ។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

-ឯកសារ- កាលប្បវត្តិ